


(https://www.prasac.com.kh/)








# ឯកអគ្គរដ្ឋទូតសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ លើកឡើងពីការរីកចម្រើនរបស់រាជធានីភ្នំពេញ ជាមួយនឹងបញ្ហាប្រឈមដែលត្រូវរួមគ្នាដោះស្រាយ

26/11/2019 9:30 Pm ជាតិទូទៅ (Http://kampucheathmey.com/2016/category/%e1%9e%96%e1%9f%90%e1%9e%8f%e1%9f%8c%e1%9e%98%e1%9e%b6%e1%9e%93%e1%9e%87%e1%9e%b6%e1%9e%8f%e1%9e%b7/%e1%9e%87%e1%9e%b6%e1%9e%8f%e1%9e%b7%e1%9e%91%e1%9e%bc%e1%9e%91%e1%9f%85/), ព័ត៌មានជាតិ (Http://kampucheathmey.com/2016/category/%e1%9e%96%e1%9f%90%e1%9e%8f%e1%9f%8c%e1%9e%98%e1%9e%b6%e1%9e%93%e1%9e%87%e1%9e%b6%e1%9e%8f%e1%9e%b7/) ♡ 1

ភ្នំពេញ ៖ ឯកអគ្គរដ្ឋទូតសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ប្រចាំនៅកម្ពុជា លោក Christian Berger បានលើកឡើងនិងកោតសរសើរ ពីការរីកចម្រើនរបស់រាជធានីភ្នំពេញ។ ប៉ុន្តែទន្ទឹមនឹងនោះ លោកឯកអគ្គរដ្ឋទូតក៏បានលើកឡើងនូវបញ្ហាប្រឈមមួយចំនួនផងដែរ ដើម្បីនាំដោះស្រាយ ធ្វើយ៉ាងណាឲ្យរាជធានីភ្នំពេញមួយនេះជាទីក្រុងមានភាពវ៉ៃឆ្លាត។



Kampuchea Thmey D...
3,539,478 likes
Like Page
Contact
65 friends like this

ADVERTISER




(http://855play.com/index.jsp?param=Registration)




(https://digi.com.kh/)




(http://kampucheathmey.com/2016/wp-content/uploads/2019/11/T-11-26-19-l2-full.jpg)

ការលើកឡើងរបស់លោក Christian Berger បែបនេះ ក្នុងសន្និសីទផ្សព្វផ្សាយគម្រោងលំនៅឋានដែលមានចីរភាពសម្រាប់ប្រជាជនបង្កើនគុណភាពរស់នៅក្នុងទីក្រុងនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើឡើងកាលពីព្រឹកថ្ងៃអង្គារ ១៥រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩នៅសណ្ឋាគារសាន់វេ ខណ្ឌដូនពេញ។



(http://kampucheathmey.com/2016/wp-content/uploads/2019/11/T-11-26-19-l1-full.jpg)

លោក Christian Berger បានមានប្រសាសន៍លើកឡើងថា សម្រាប់ប្រទេសកម្ពុជា ពិសេសនៅក្នុងរាជធានីភ្នំពេញ បើយើងនិយាយពីឆ្នាំ ១៩៩១ និងឆ្នាំ២០១៩នេះ គឺរាជធានីភ្នំពេញមានការខុសប្លែកគ្នាខ្លាំងណាស់ ដោយនៅឆ្នាំ២០១៩នេះរាជធានីភ្នំពេញមានអគារខ្ពស់រាប់សិបជាន់ជាច្រើន មានរថយន្តជាច្រើនបានរត់នៅលើដងផ្លូវ ដែលនេះបានបង្ហាញពីការរីកចម្រើនលើគ្រប់វិស័យ ប្រជាពលរដ្ឋទទួលបាននូវជីវភាពល្អប្រសើរជាងមុន ។ ប៉ុន្តែទន្ទឹមនឹងនេះក៏មានការខូចបង់ទៅវិញផងដែរ ដោយការអភិវឌ្ឍនេះវាបានធ្វើឲ្យកើនឡើងនូវកំដៅ ការបាត់បង់នូវព្រៃក បឹងជាដើម។ នេះជាហានិភ័យមួយដែលយើងទាំងអស់គ្នាគួរតែដឹងនិងស្វែងយល់ឲ្យបានច្បាស់ ពោលគឺកាលណាយើងធ្វើការអភិវឌ្ឍ ក្រុងមួយយើងត្រូវតែគិតមុនពីហានិភ័យនេះ។



## ព័ត៌មានជាតិថ្មីៗ



ជាតិទូទៅ ព័ត៌មានជាតិ ព័ត៌មានថ្មីៗ

សម្ដេចតេជោ៖ មន្ទីរពេទ្យកម្ពុជា មានសមត្ថភាពព្យាបាលដោះដូរក្រលៀនបាន

16/12/2019 3:04 Pm



នយោបាយ ព័ត៌មានថ្មីៗ

បទវិចារណកថា៖ការលើកឡើងរបស់សារព័ត៌មាន «គោលនយោបាយបរទេស»ប្រាសចាកការពិតនៅកម្ពុជា

16/12/2019 10:56 Am



ព័ត៌មានថ្មីៗ សន្តិសុខ និងសង្គម

បុរសចំណាស់ម្នាក់ ត្រូវបានសម្លាប់ ដោយសារមនុស្សវិកលចរិក វាយនឹងដំបង

15/12/2019 2:49 Pm



ព័ត៌មានថ្មីៗ សន្តិសុខ និងសង្គម

ស្ពានថ្មមួយកន្លែងឆ្លងកាត់ស្ទឹងសង្កែ ត្រូវសាលាខេត្តផ្អាកមិនឱ្យធ្វើដំណើរ

15/12/2019 12:38 Pm



ជាតិទូទៅ ព័ត៌មានជាតិ ព័ត៌មានថ្មីៗ

លោក ហ៊ុន ម៉ាណែត ជួបសំណេះសំណាលជាមួយនិស្សិតខ្មែរ ដែលសិក្សានៅប្រទេសអូស្ត្រាលី និងនូវែលហ្សេឡង់

14/12/2019 5:41 Pm



ព័ត៌មានថ្មីៗ សន្តិសុខ និងសង្គម

ខេត្តកំពតផ្អាកបណ្ដោះអាសន្នមិនឱ្យរថយន្តដឹកដីធំៗ និងការដ្ឋានវាយថ្មគ្រប់ប្រភេទ អំឡុងរៀបចំបុណ្យសមុទ្រ

14/12/2019 12:28 Pm



KPT PLUS ជីវិត ព័ត៌មានថ្មីៗ សុខភាព

ធ្លាប់សុខៗលែងមានអារម្មណ៍ធ្វើការអត់? នេះហើយជាមូលហេតុ

14/12/2019 11:48 Am




(http://kampucheathmey.com/2016/wp-content/uploads/2019/11/T-11-26-19-13-full.jpg)

លោក Christian Berger បានបញ្ជាក់ផងដែរថា ការបង្កើតឲ្យមានកម្មវិធីខាងលើនេះ ឡើងគឺ ដើម្បីពិភាក្សាលើបញ្ហាមួយចំនួន ដូចជា ការបម្រែបម្រួលអាកាសធាតុ ការកើនឡើងនូវកំដៅ ការកើនឡើងនូវតម្រូវការប្រជាពលរដ្ឋ ដោយនៅរាជធានីភ្នំពេញ តាមការប៉ាន់ប្រមាណនៅក្នុងឆ្នាំ២០៣០ខាងមុខនេះ ប្រជាពលរដ្ឋអាចនឹងកើនឡើង ៣លាននាក់ពេលនោះផ្ទះសម្បែងអគារធំៗ ក៏ត្រូវតែកើនឡើងទៅតាមនោះដែរ។



(http://kampucheathmey.com/2016/wp-content/uploads/2019/11/T-11-26-19-15-full.jpg)

លោកថា ការបង្កើតឲ្យមានកម្មវិធីនេះឡើង គឺដើម្បីឲ្យយុវជនជំនាន់ក្រោយទាំងអស់បានដឹងពីផលប៉ះពាល់ ពោលគឺនៅមុនពេលធ្វើការអភិវឌ្ឍន៍ក្រុងគឺត្រូវតែផ្សារភ្ជាប់និងគិតគូរអំពីបញ្ហាបរិស្ថាន ដោយបង្កើតឲ្យមានជាគំនិតដាំដើមឈើឲ្យក្លាយជាទីក្រុងមានផ្ទៃបៃតង។ លោកចង់ឲ្យការសាងសង់អគារមានភាពវៃឆ្លាត និងចង់ឲ្យមានការអភិវឌ្ឍន៍ទីក្រុងមានភាពវ័យឆ្លាត។

អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញលោកស៊ុយ សេរិទ្ធ នៅក្នុងឱកាសនោះបានមានប្រសាសន៍លើកឡើងថា រាល់ការអភិវឌ្ឍន៍របស់រាជធានីភ្នំពេញ គឺយើងបានគិតគូរទៅលើរឿងបរិស្ថានទាំងអស់ ដោយបរិស្ថានគឺជាដង្ហើមរស់របស់មនុស្ស។

ជាការគិតគូរ របស់រដ្ឋបាលរាជធានីភ្នំពេញ រាល់ការសាងសង់អគារខុនដូបុរី បើកម្ចាស់ទាំងនោះមិនគិតគូរដល់ការដាំដើមឈើនៅក្នុងបុរីក៏ដូចជាខុនដូទាំងនោះទេ គឺមិនអនុញ្ញាតឲ្យសាងសង់អគារទាំងនោះទេ ។ លោកបញ្ជាក់ថាការអភិវឌ្ឍន៍ទីក្រុងមួយបើមិនគិតពីបញ្ហាបរិស្ថានទេគឺទទួលបរាជ័យហើយ។



FEATURED
KPT PLUS
ជីវិត
ព័ត៌មានថ្មីៗ
បី
ម៉ាត
យ៉ាង
ខ្លី
ទៅកាន់
អ្នក
ដែល
ក្បត់
យើង



១
14/12/2019
11:40
Am



(http://kampucheathmey.com/2016/wp-content/uploads/2019/11/T-11-26-19-l6-full.jpg)

លោកបន្តថា សម្រាប់រាជធានីភ្នំពេញ យើងបានធ្វើការស្ដាល្ង ក៏ដូចជាយកទឹកចេញពីរាជធានី ក្នុងមួយឆ្នាំអស់ថវិកាប្រមាណជា១៥លានដុល្លារ ខណៈដែលយើងទទួលប្រាក់ ពីប្រជាពលរដ្ឋលើការងារនេះ បានប្រមាណតែបីលានដុល្លារតែប៉ុណ្ណោះក្នុងមួយឆ្នាំ។

លោកបានបញ្ជាក់ផងដែរថា យើងរស់នៅជាមួយបរិស្ថានបើយើងបំផ្លាញបរិស្ថានគឺចប់ហើយ ។ ដូច្នេះហើយទើបយើងរួមគ្នាថែរក្សាបរិស្ថានជាមួយនឹងការបណ្ដុះបណ្ដាលក្មេងៗជំនាន់ក្រោយឲ្យពួកគាត់បានយល់ដឹងឲ្យច្បាស់ពីអត្ថប្រយោជន៍និងផលប៉ះពាល់នៃបរិស្ថាននេះ៕
ស្រីរ័ត្ន



(http://kampucheathmey.com/2016/wp-content/uploads/2019/11/T-11-26-19-l4-full.jpg)

FACEBOOK TWITTER GOOGLE+ LINKEDIN TUMBLR MERKEN
MAIL

*Previous Post*
« ផ្កាម្លិះ ជាប្រភពចំណូលប្រចាំថ្ងៃរបស់កសិករ ក្នុងភូមិកោះក្របី

*Next Post*
រដ្ឋសភា អនុម័តសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០២០ និងសេចក្តីព្រាងច្បាប់ចំនួន ៣ ផ្សេងទៀត »

## តុលា

ប្រសិនបើ លោក លោកស្រីចង់ចែករំលែកនូវព័ត៌មានទាន់ហេតុការណ៍ផ្សេងៗ សូមផ្ញើអ៊ីម៉ែលមកកាន់អាសយដ្ឋានដូចដែលបានបង្ហាញខាងក្រោម។ សម្រាប់ការផ្សាយពាណិជ្ជកម្មលើគេហទំព័រនេះ សូមទំនាក់ទំនងតាមលេខទូរស័ព្ទ: 012 454 575 និង 012 499 114

ការិយាល័យទំនាក់ទំនង

អាស័យដ្ឋាន៖ ផ្ទះលេខ ៤០ ផ្លូវ ៣៣៤, បឹងកេងកង១, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខ: (៨៥៥) ០៦៩ ២៣៩ ២៣២
ទូរសារលេខ: (៨៥៥) ២៣ ៧២៦ ៦១៧

រក្សាសិទ្ធិដោយ កម្ពុជាថ្មី